- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

ប្រការ ១.-

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសិក្សានិមិត្តសញ្ញារាជធានី ខេត្ត ដែលមានសមាសភាពដូចខាងក្រោម ÷

១-តំណាងក្រសួងមហាផ្ទៃ	ប្រធាន
២-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	អនុប្រធាន
៣-តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៤-តំណាងក្រសួងពាណិជ្ជកម្ម	សមាជិក
៥-តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក.../

៦-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៧-តំណាងក្រសួងទេសចរណ៍	សមាជិក
៨-តំណាងក្រសួងព័ត៌មាន	សមាជិក
៩-តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
១០-តំណាងក្រសួងធម្មការ និងសាសនា	សមាជិក
១១-តំណាងរាជបណ្ឌិតសភាកម្ពុជា	សមាជិក
១២-អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ	សមាជិក

ប្រការ ២.-

ក្រុមការងារអន្តរក្រសួង មានភារកិច្ចដូចខាងក្រោម ៖

- ណែនាំរាជធានី ខេត្តឱ្យធ្វើការសិក្សា ស្រាវជ្រាវអំពីនិមិត្តសញ្ញានៃរាជធានី ខេត្តរបស់ខ្លួន
- ពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃលើខ្លឹមសារ និងអត្ថន័យនៃនិមិត្តសញ្ញារាជធានី ខេត្ត
- រៀបចំសេចក្តីព្រាងលិខិតស្តីពីការកំណត់និមិត្តសញ្ញារាជធានី ខេត្ត ដើម្បីក្រសួងមហាផ្ទៃចាត់ចែងតាមនីតិវិធី ។

ប្រការ ៣.-

ប្រធានក្រុមការងារអន្តរក្រសួងមានសិទ្ធិអញ្ជើញអនុប្រធាន និងសមាជិកក្រុមការងារអន្តរក្រសួង ឱ្យចូលរួមប្រជុំ តាមការចាំបាច់ ។

ប្រការ ៤.-

ការចំណាយផ្សេងៗក្នុងការបំពេញភារកិច្ចរបស់ក្រុមការងារអន្តរក្រសួងជាបន្ទុករបស់ក្រសួងមហាផ្ទៃ ។

ប្រការ ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រាជបណ្ឌិតសភាកម្ពុជា និងអគ្គនាយករដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ : ៦៣៣២ ប្រក

លិខិតចូល

ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១០

ប្រកាស

ស្តីពី

ការកំណត់តួនាទី និងភារកិច្ច

របស់ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្ត នៃក្រុមប្រឹក្សានីតិកម្ម

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យ លេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យ លេខ ១៧៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម

សម្រេច

ប្រការ ១.-

សមាជិកក្រុមប្រឹក្សានីតិកម្មម្នាក់ៗ ត្រូវបានចាត់តាំងបញ្ចូលទៅក្នុងក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តនីមួយៗ ដូចមានចែងក្នុងអនុក្រឹត្យ លេខ ១៧៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ។

ក្រុមស្រាវជ្រាវនីមួយៗ ត្រូវមានសមាជិកក្រុមប្រឹក្សានីតិកម្ម យ៉ាងតិច ០៥រូប ដឹកនាំដោយប្រធាន ០១រូប ចាត់តាំងឡើងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម។

ក្នុងករណីប្រធានអវត្តមាន ប្រធានក្រុមប្រឹក្សានីតិកម្ម ត្រូវចាត់តាំងសមាជិកក្រុមប្រឹក្សានីតិកម្មណាម្នាក់នៅក្នុងក្រុមស្រាវជ្រាវ ជាប្រធានស្តីទីជំនួស។

ប្រការ ២.-

តួនាទី និងភារកិច្ច របស់ក្រុមស្រាវជ្រាវនីមួយៗ នៃក្រុមប្រឹក្សានីតិកម្ម មានដូចខាងក្រោម ÷

ក-ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តនគរបាល

- សិក្សាស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្ត ដែលមិនស្របច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដើម្បីស្នើសុំគោលការណ៍ កែសម្រួល ធ្វើវិសោធនកម្ម
- សហការ និងចូលរួមជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ក្នុងការងារកសាង និងពិនិត្យលិខិតបទដ្ឋានគតិយុត្តនគរបាលជាតិ
- តាមដានលើការអនុវត្តនិងការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនគរបាលជាតិ
- សហការជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ ផ្នែកនគរបាលជាតិ ទាំងនៅថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានារបស់នគរបាលដែលចាំបាច់។

ខ-ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តរដ្ឋបាល

- សហការ និងចូលរួមជាមួយអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្នុងការលើកផែនការកែសម្រួល ឬកសាងលិខិតបទដ្ឋានគតិយុត្តនានា ដែលមានការចាំបាច់
- សហការជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃផ្នែករដ្ឋបាលស៊ីវិល ក្នុងការផ្តល់យោបល់ និងកសាងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ក្នុងករណីចាំបាច់
- ពិនិត្យខ្លឹមសារសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនានា ដែលអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ឬអង្គភាពផ្សេងៗ ចំណុះក្រសួងមហាផ្ទៃកំពុងតាក់តែងនិង/

បានតាក់តែងរួចហើយមុននឹងដាក់ជូនមតិថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ

-សហការតាមដាន ត្រួតពិនិត្យដីកា និងសេចក្តីសម្រេចនានា របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សហការជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃផ្នែករដ្ឋបាលស៊ីវិលទាំងនៅថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដើម្បីផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដែលចាំបាច់

គ_ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តក្រសួង ស្ថាប័ន នានា

-សិក្សាស្រាវជ្រាវសេចក្តីព្រាង និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ តាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ

-សហការរៀបចំបំពេញបែបបទក្នុងការបញ្ជូនសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យនានាទៅរាជរដ្ឋាភិបាល ក្រោយពីមានការសម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-ចូលរួមក្នុងគណៈកម្មាធិការ ឬ ក្រុមការងារតាក់តែងច្បាប់ ឬ អង្គភាពជំនាញនិងក្រសួង ស្ថាប័ន នានា តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ

-ចូលរួមក្នុងការងារកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

-សហការរៀបចំការបណ្តុះបណ្តាលដល់មន្ត្រីក្រោមឱវាទរបស់ក្រសួងមហាផ្ទៃទាំងនៅថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់លើវិស័យច្បាប់

-តំណាងក្រសួងមហាផ្ទៃក្នុងការចូលរួមប្រជុំជាមួយក្រសួង ស្ថាប័ននានា របស់រាជរដ្ឋាភិបាលតាមការចាត់តាំងពីថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ

ឃ_ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

-សិក្សា និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួង អំពីសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងសន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ

-សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួង លើអនុស្សរណៈរបស់អង្គការជាតិ អន្តរជាតិនានា ដែលត្រូវចុះហត្ថលេខាជាមួយក្រសួងមហាផ្ទៃ

-សិក្សាស្រាវជ្រាវប្រព័ន្ធច្បាប់នៅតាមបណ្តាប្រទេសមួយចំនួនតាមការចាំបាច់

-ទំនាក់ទំនងជាមួយបណ្តាស្ថានទូត សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ដើម្បីសិក្សាស្រាវជ្រាវលិខិតបទដ្ឋាននានា

ប្រការ ៣.-

បទប្បញ្ញត្តិដូចមានចែងក្នុងចំណុច "ក" "ខ" "គ" និង "ឃ" នៃប្រការ២ ត្រូវបំពេញតួនាទី និងភារកិច្ចតាមការចាត់តាំងរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម។

ប្រការ ៤.-

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ ប្រធានក្រុមប្រឹក្សានីតិកម្ម និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១០

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

កន្លែងទទួល :

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"

-ដូចប្រការ៤ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ : ៤១១ ប្រក

លិខិតចូល

ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ 2010

ប្រកាស

ស្តីពី

ការកំណត់ភារកិច្ច និងរចនាសម្ព័ន្ធ

របស់លេខាធិការដ្ឋាន នៃក្រុមប្រឹក្សានីតិកម្ម

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យ លេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៧៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ
- បានឃើញប្រកាស លេខ ០៩៥ ប្រក ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធរបស់ទីស្តីការក្រសួងមហាផ្ទៃ
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម

សម្រេច

ប្រការ ១.-

ត្រូវបានកំណត់លេខាធិការដ្ឋាននៃក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើនាយកដ្ឋានធានារបស់ក្រសួងមហាផ្ទៃ។

លេខាធិការដ្ឋាន នៃក្រុមប្រឹក្សានីតិកម្ម ដឹកនាំដោយប្រធាន ០១រូប និងមាន អនុប្រធានមួយចំនួនជាជំនួយការ។

ប្រការ ២.-

លេខាធិការដ្ឋាន នៃក្រុមប្រឹក្សានីតិកម្ម មានភារកិច្ច÷

- ធ្វើជាសេនាធិការជូនក្រុមប្រឹក្សានីតិកម្ម
- ចូលរួមធ្វើកំណត់ហេតុកិច្ចប្រជុំក្រុមប្រឹក្សានីតិកម្ម
- ពិនិត្យលិខិតស្នាម និងឯកសារផ្សេងៗដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សានីតិកម្ម ពិនិត្យសម្រេច
- រៀបចំកម្មវិធីការងារ បេសកកម្ម ពិធីការផ្សេងៗក្នុងក្រុមប្រឹក្សានីតិកម្ម
- គ្រប់គ្រងឯកសាររបស់ក្រុមប្រឹក្សានីតិកម្ម
- ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានផ្សេងៗរបស់រាជរដ្ឋាភិបាល តាមការណែនាំ របស់អង្គភាព
- គ្រប់គ្រងការងារបុគ្គលិកក្នុងក្រុមប្រឹក្សានីតិកម្ម
- លើកផែនការថវិកា ស្បៀង ប្រេងឥន្ធនៈ និងសម្ភារៈបរិក្ខារ សម្រាប់ផ្គត់ផ្គង់ជូន មន្ត្រីក្រុមប្រឹក្សានីតិកម្ម
- គ្រប់គ្រងទ្រព្យសម្បត្តិ ធ្វើបញ្ជីសារពើភ័ណ្ឌ និងផ្គត់ផ្គង់សម្ភារៈ បរិក្ខារ មធ្យោ បាយ សម្រាប់បម្រើការងារក្នុងក្រុមប្រឹក្សានីតិកម្ម
- បំពេញភារកិច្ចផ្សេងៗទៀតដែលប្រធានក្រុមប្រឹក្សានីតិកម្មប្រគល់ឱ្យ។

ប្រការ ៣.-

រចនាសម្ព័ន្ធនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ត្រូវបានកំណត់ដូចខាងក្រោម÷

១-ការិយាល័យរដ្ឋបាល-សរុប

២-ការិយាល័យកិច្ចការផ្ទៃក្នុង

៣-ការិយាល័យទំនាក់ទំនងអន្តរវិស័យ

៤-ការិយាល័យបណ្ណាល័យ និងរាជកិច្ច

ប្រការ ៤.-

តួនាទី និងភារកិច្ចការិយាល័យចំណុះលេខាធិការដ្ឋាន ÷

១-ការិយាល័យរដ្ឋបាល-សរុប

- គ្រប់គ្រងការងាររដ្ឋបាល លិខិតចូល ចេញ ចូកសរុបរបាយការណ៍ប្រចាំខែ /

ត្រីមាស ឆមាស ប្រាំបួនខែ និងឆ្នាំ របស់ក្រុមប្រឹក្សានីតិកម្ម

- គ្រប់គ្រងការងារបុគ្គលិក និងរៀបចំបៀវត្សជូនមន្ត្រី នៃក្រុមប្រឹក្សានីតិកម្ម
- ទំនាក់ទំនងកិច្ចការរដ្ឋបាលជាមួយនាយកដ្ឋាន អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងទទួលរៀបចំពិធីការក្នុងក្រុមប្រឹក្សានីតិកម្ម
- លើកផែនការថវិកា សម្ភារៈ សំលៀកបំពាក់ ប្រេងឥន្ធនៈ តាមការកំណត់របស់ក្រសួង
- ផ្ញើបញ្ជីសារពើភ័ណ្ឌ គ្រប់គ្រងឯកសារដែលពាក់ព័ន្ធការងារភស្តុភារ និងគណនេយ្យរបស់ក្រុមប្រឹក្សានីតិកម្ម
- ទំនាក់ទំនងស្នើសុំថវិកា ប្រេងឥន្ធនៈ ធ្វើរបាយការណ៍ទូទាត់ចំណូល ចំណាយថវិកា សម្ភារៈ និងបរិក្ខារផ្សេងៗ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ សម្រាប់ផ្តល់ជូនមន្ត្រីក្រុមប្រឹក្សានីតិកម្ម
- ទទួលភារកិច្ចផ្សេងៗទៀត ដែលលេខាធិការដ្ឋានប្រគល់ឱ្យ។

២-ការិយាល័យកិច្ចការផ្ទៃក្នុង

- សហការស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនគរបាលជាតិ និងរដ្ឋបាលស៊ីវិល
- សហការរៀបចំចងក្រងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការនគរបាល និងរដ្ឋបាលស៊ីវិល
- រក្សាទុកនូវរាល់លិខិតបទដ្ឋានផ្សេងៗ ដែលពាក់ព័ន្ធនឹងកិច្ចការនគរបាល និងរដ្ឋបាលស៊ីវិល
- ចងក្រងជាឯកសារនូវខ្លឹមសារលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងនគរបាលជាតិ និងរដ្ឋបាលស៊ីវិល
- ទទួលភារកិច្ចផ្សេងៗទៀត ដែលលេខាធិការដ្ឋានប្រគល់ឱ្យ។

៣-ការិយាល័យទំនាក់ទំនងអន្តរវិស័យ

- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន សង្គមស៊ីវិល និង ដៃគូអភិវឌ្ឍន៍នានា ដើម្បីសិក្សាស្រាវជ្រាវឯកសារ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងស្ថាប័ន ទាំងនោះ
- សហការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័ននានា ក្នុងករណីចាំបាច់ ៤

- រក្សាទុកឯកសារលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័ន
- ទទួលភារកិច្ចផ្សេងៗទៀតដែលលេខាធិការដ្ឋានប្រគល់ឱ្យ។

៤-ការិយាល័យបណ្ណាល័យ និងរាជកិច្ច

- គ្រប់គ្រង រក្សាឯកសារ លិខិតបទដ្ឋានគតិយុត្តនានា សារាចរ សេចក្តីណែនាំ កិច្ចព្រមព្រៀង កិច្ចសន្យា ពិធីសារ អនុសញ្ញា ច្បាប់អន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តនានា
- រៀបចំចងក្រងសៀវភៅ តូច ធំ ដើម្បីតម្កល់ទុកជាឯកសារ និងបោះពុម្ព
- រៀបចំបែងចែកសៀវភៅរាជកិច្ចជូនអង្គភាពនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅតាមរាជធានី ខេត្ត
- ទទួលភារកិច្ចផ្សេងៗទៀតដែលលេខាធិការដ្ឋានប្រគល់ឱ្យ។

ប្រការ ៥.-

ការិយាល័យនីមួយៗ ដឹកនាំដោយ នាយការិយាល័យ ០១រូប និងមាននាយរងការិយាល័យមួយចំនួនជាជំនួយការ។

ប្រការ ៦.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៧.-

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ ប្រធានក្រុមប្រឹក្សានីតិកម្ម និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០១០

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៧៥៤ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ប៉ុល វាសនា អ៊ីមផត អិចផត**

POL VEASNA IMPORT EXPORT Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 13747/09P ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ប៉ុល វាសនា** ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី **ឆេង ស្រីទី** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង ។

៥- កម្មវត្ថុអាជីវកម្ម :

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ នាំចូលឱសថសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាវេចខ្ចប់ និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីស្តីទី

ភិម ស៊ីថន

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាខេត្តស្វាយរៀង
- មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង " មុខការ "

ស.ជ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៧៥៩ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

សាខាក្រុមហ៊ុនបរទេសមួយត្រូវបានចុះបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុនដើម : T.T.D ADVERTISING & CONSTRUCTION CORPORATION.

នាមករណ៍របស់សាខា : **សាខាក្រុមហ៊ុន ធី.ធី.ឌី អ៊ែតវើថាយស៊ីង & ខនស្រ្តាក់សិន ខបភើរេសិន**

Branch of T. T. D ADVERTISING & CONSTRUCTION CORPORATION

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 538/09B ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៩

២- នាយកសាខាក្រុមហ៊ុន : លោក DUONG HA

៣- ទីស្នាក់ការសាខា : លេខ ៥០២ G -៥០២ H ផ្លូវលេខ ៩៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

៤- កម្មវត្ថុអាជីវកម្ម : -សេវាផ្សាយពាណិជ្ជកម្ម

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហ័រណ អាហ័រណទំនិញ ពិសេស គ្រឿងអគ្គិសនី គ្រឿងសំណង់ គ្រឿងសង្ហារឹម គ្រឿងឧបភោគបរិភោគ និងគ្រឿងសំអាងកាយ

-សេវាពិគ្រោះយោបល់លើផ្នែកសំណង់

៥- សញ្ជាតិក្រុមហ៊ុន : វៀតណាម

រាល់ដំណាច់ឆ្នាំនីមួយៗ នាយកសាខាក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់សាខាពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ចាម ប្រសិទ្ធ

ចម្លងជូន:

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ -ក្រសួងពត៌មាន
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ផ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៧៦២ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០០៩

ដេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ដុង ហូ ខមភេនី (ឌី អេច)**
DONG HO COMPANY Ltd. (D H)

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 13739/09P** ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ដុងហូ ឆយ**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្លូវជាតិលេខ ៥ ភូមិខ្ទង ឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្តាល ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកិច្ចការដើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីស្ដីទី

ក៏ម-ស៊ីថន

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តកណ្តាល
- មន្ទីរពាណិជ្ជកម្មខេត្តកណ្តាល "មុខការ"
- ឯកសារ -កាលប្បវត្តិ

ស.ផ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៧៦៣ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហាតរ៉ក់ កាហ្វេ (ខេមបូឌា) លីមីធីត**
HARD ROCK CAFÉ (CAMBODIA) LIMITED

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 5863/09E** ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **CHEN LIP KEONG**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ណាហ្គាវើលដ៍ ហូថេល ផ្លូវសួនច្បារសម្តេចហ៊ុនសែន សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេស នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-សេវាផ្នែកពត៌មានវិទ្យា

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត ទីភ្នាក់ងារទេសចរណ៍

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ញើនិងថែរក្សាទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

កឹម ស៊ីថន

<u>ចម្លងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
  ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ផ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៧៦៥ ពណ.ចបព

ភ្នំពេញថ្ងៃទី០៤ ខែកក្កដា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេស ស៊ី អិន ខបភើរេសិន**

S C N CORPORATION Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 13734/09P** ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ស្រេង ន័យណារ៉ា**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១២.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៣៦ Eo ផ្លូវលេខ ១៥ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ និហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-ផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត និងវីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាដឹកជញ្ជូនទំនិញនិងចែកចាយទំនិញ
-សេវាយកតំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

ចាម_ប្រសិទ្ធ

<u>**ចម្លងជូន**</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ស.ផ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៧៦៤ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន	: **សាន់ ផៅវ័រ (ខេមបូឌា)**
	SUN POWER (CAMBODIA) Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	: Co. 5950/09E ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩
មានទ្រង់ទ្រាយជា	: ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត
២- អភិបាលក្រុមហ៊ុន	: លោក WOLF JOACHIM WALTER ប្រធានក្រុមប្រឹក្សាភិបាល
	លោក REIBER CHRISTIAN អភិបាល
៣- ដើមទុនក្រុមហ៊ុន	: ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន	: ភូមិ ៤ ឃុំអូរត្រេស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។
៥- កម្មវត្ថុអាជីវកម្ម	: -ពាណិជ្ជកម្ម :ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
	-ការជួលដាក់ឃ្លាំងទូរផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
	-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
	-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
	-បើកសាលារៀន
	-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
	-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
	-សេវាផ្សព្វផ្សាយពាណិជ្ជកម្ម
	-បោះពុម្ពផ្សាយ
	-ផលិតខ្សែភាពយន្ត វីដេអូ CD
	-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ចេញ ចូល ចែកចាយទំនិញ
	-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
	-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
	-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីស្តីទី

ភឹម ស៊ីថន

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាខេត្តព្រះសីហនុ
- មន្ទីរពាណិជ្ជកម្មខេត្តព្រះសីហនុ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ក ស ន